**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**រវាង**

**រោងចក្រ ស៊ីស៊ី (ខេមបូឌា) អ៊ិនធើណេសិនណាល ៦.ក**

**និង**

**តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ**

**រោងចក្រ ស៊ីស៊ី (ខេមបូឌា) អ៊ិនធើណេសិនណាល ៦.ក**

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២៣ វេលាម៉ោង ១០:០០ នៅក្នុងរោងចក្រ **ស៊ីស៊ី (ខេមបូឌា) អ៊ិនធើណេសិនណាល ៦.ក** មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិតសហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារគ្មានការបញ្ជាទិញ ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ៤៦៨នាក់ (ស្រី ៣៥២នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៤៦៨នាក់ (ស្រី ៣៥២នាក់) រយៈពេលចំនួន **៦១ថ្ងៃ** គឺចាប់ពី **ថ្ងៃ០១ ខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ ថ្ងៃ៣១ ខែតុលា ឆ្នាំ២០២៣** នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះកម្មករនិយោជិតបានឯកភាពទទួលយកការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឧបត្ថម្ភចំនួន **៣០ដុល្លារ** ក្នុងរយៈពេល**៣០ថ្ងៃ** ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមហ៊ុននឹងបើកជូនប្រាក់ឧបត្ថម្ភនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភ ៣០ដុល្លារ រយៈពេលព្យួរកិច្ចសន្យាការងារ ៣១ថ្ងៃបន្ទាប់ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ ក្រុមហ៊ុននឹងបើកជូនប្រាក់ឧបត្ថម្ភនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ ចំពោះប្រាក់ឧបត្ថម្ភក្រុមហ៊ុនបើកតាមរយៈធនាគារវីងជូនបងប្អូនកម្មករនិយោជិតម្នាក់ៗ។ ស្របតាមសេចក្តីណែនាំលេខ ០២០/២៣កប/សណនខលចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣។

អង្គប្រជុំបានចប់វេលាម៉ោង១០ និង ៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ភ្នំពេញ,ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២៣

**តំណាងកម្មករ និង តំណាងសហជីព**

ចាន់ បូរី ចំរើន សម្ផស្ស ជួន ស្រស់ ភី សុខឃី

សុខ ម៉ានិត ចំរើន សុខសូរិយា យ៉ៅប សុវណ្ណ អន ផល្លី

ជ. **នាយកក្រុមហ៊ុន**

ក្រុមហ៊ុន ស៊ីស៊ី (ខេមបូឌា) អ៊ិនធើណេសិនណាល ៦.ក
SUSU (CAMBODIA) INTERNATIONAL CO.,LTD
KINGDOM OF CAMBODIA

Scanned with CamScanner